# វគ្គបណ្តុះបណ្តាលស្តីពីទស្សនីយកម្មទិន្នន័យក្នុងសារព័ត៌មាន

**ថ្ងៃទី២៩-៣០ ខែសីហា ឆ្នាំ២០២៤**

**ទីតាំង៖ រាជធានីភ្នំពេញ**

## សេចក្តីផ្តើម

ទស្សនីយកម្មទិន្នន័យ គឺជាវិធីសាស្ត្រដ៏មានប្រសិទ្ធភាពរបស់អ្នកសារព័ត៌មាន នៅក្នុងទិដ្ឋភាពប្រព័ន្ធផ្សព្វផ្សាយនាពេលបច្ចុប្បន្ននេះ ដែលរយៈពេលនៃការយកចិត្តទុកដាក់របស់អ្នកអានគឺខ្លី និងមានភាពស្មុគស្មាញច្រើន។ វាគឺជាឧបករណ៍មួយដែលអាចឱ្យរឿងរ៉ាវមានកាន់តែមានអត្ថន័យ ដោយផ្សារភ្ជាប់ជាមួយអ្នកអានតាមរយៈរូបភាពដែលមានអត្ថន័យ និងងាយស្រួលយល់សម្រាប់ពួកគេ។ អ្នកសារព័ត៌មានដែលស្ទាត់ជំនាញទស្សនីយកម្មទិន្នន័យ អាចស្វែងរកព័ត៌មានបានយ៉ាងងាយស្រួលពីប្រភពផ្សេងៗ ហើយបង្ហាញវាតាមរបៀបដែលមិនត្រឹមតែទាក់ទាញប៉ុណ្ណោះទេ ប៉ុន្តែក៏អាចយល់បានភ្លាមៗផងដែរ។ វគ្គបណ្តុះបណ្តាលនឹងបង្កើនដំណេះដឹងរបស់អ្នកសារព័ត៌មានក្នុងការប្រើប្រាស់ទស្សនីយកម្មទិន្នន័យជំនាញនិទានរឿងដែលទាក់ទាញការចាប់អារម្មណ៍របស់អ្នកអាន និងបន្សល់ទុកនូវសញ្ញាណយ៉ាងរហ័សលើការវិវត្តនៃវិស័យសារព័ត៌មាននៅកម្ពុជា។

ជាមួយនឹងវគ្គបណ្តុះបណ្តាល "ទស្សនីយកម្មទិន្នន័យក្នុងសារព័ត៌មាន" អ្នកអាចចាប់ផ្តើមការផ្លាស់ប្តូរសារព័ត៌មានដែលស្វែងយល់ពីចំនុចប្រសព្វនៃទិន្នន័យ និងការនិទានរឿង។ ទស្សនីយកម្មទិន្នន័យ គឺជាសិល្បៈនៃការបំប្លែងទិន្នន័យដើមទៅជារូបភាពដែលគួរឱ្យទាក់ទាញ ហើយវាជួយក្នុងការពន្លឿនការនិទានរឿងផងដែរ។ ក្នុងយុគសម័យដែលព័ត៌មានជាច្រើនវាយលុក អ្នកសារព័ត៌មានដែលមានជំនាញទស្សនីយកម្មទិន្នន័យ មានសមត្ថភាពក្នុងការផ្លាស់ប្តូរសំណុំទិន្នន័យស្មុគស្មាញ ទៅជាក្រាហ្វ គំនូសតាងអន្តរកម្ម និងផែនទីដែលងាយស្រួលយល់។ វគ្គបណ្តុះបណ្តាលនេះនឹងផ្តល់នូវឱកាសមួយក្នុងការរួមបញ្ចូលគ្នានូវជំនាញសារព័ត៌មានប្រកបដោយភាពច្បាស់លាស់ ជាមួយនឹងភាពជាក់លាក់នៃទិន្នន័យ ដែលជាសក្តានុពលនៃការនិទានរឿងឱ្យទាក់ទាញ ផ្តល់ព័ត៌មាន និងបំផុសគំនិត។

## គោលបំណង

គោលបំណងនៃវគ្គបណ្តុះបណ្តាល "ទស្សនីយកម្មទិន្នន័យក្នុងសារព័ត៌មាន" គឺដើម្បីផ្តល់បន្ថែមឱ្យអ្នកសារព័ត៌មាននូវជំនាញក្នុងការបញ្ចូលទស្សនីយកម្មទៅក្នុងនិទានរឿងរបស់ពួកគេ ដែលអាចឱ្យពួកគេបញ្ជូនព័ត៌មាន ទាក់ទាញអ្នកអាន និងបង្ហាញការនិទានរឿងកាន់តែស៊ីជម្រៅតាមរយៈក្រាហ្វិកដែលមានឥទ្ធិពល និងអាចចូលប្រើបាន។

## តើអ្នកនឹងរៀនអ្វី?

- **ស្វែងយល់ពីទិន្នន័យ៖** ស្វែងយល់ពីរបៀបដែលទិន្នន័យតំណាងឱ្យតថភាពពិត។ ស្វែងយល់ពីប្រភេទទិន្នន័យ រចនាសម្ព័ន្ធទិន្នន័យ និងទ្រង់ទ្រាយរបស់វា ដើម្បីយល់ពីការរៀបចំទិន្នន័យសម្រាប់ការធ្វើទស្សនីយកម្ម។

- **គោលការណ៍ទស្សនីយកម្មទិន្នន័យ៖** ស្វែងយល់ពីតួនាទីនៃទស្សនីយកម្មទិន្នន័យនៅក្នុងសារព័ត៌មាន។ វិធីជ្រើសរើសប្រភេទទស្សនីយកម្ម ឱ្យបានត្រឹមត្រូវទៅតាមគោលបំណងដែលចង់បាន ហើយស្វែងយល់ពីប្រភេទទស្សនីយកម្មដែលគេប្រើជាទូទៅ។
- **គោលការណ៍រចនាក្រាហ្វ៖** រៀនពីរបៀបរចនាក្រាហ្វឱ្យបានល្អ ហើយធ្វើឱ្យការបង្ហាញទស្សនីយកម្មរបស់អ្នកមានភាពច្បាស់លាស់សម្រាប់អ្នកអាន។
- **សេចក្តីណែនាំអំពី Flourish៖** ណែនាំអំពីឧបករណ៍ និងវិធីបង្កើតទស្សនីយកម្មទិន្នន័យជាមួយវា។
- **អនុវត្តទស្សនីយកម្មទិន្នន័យជាមួយ Flourish៖** រៀនបង្កើតទស្សនីយកម្មទិន្នន័យដោយប្រើឧបករណ៍ Flourish

## តើអ្នកណាគួរតែចូលរួមវគ្គបណ្តុះបណ្តាលនេះ?

- អ្នកសារព័ត៌មានដែលមានការយល់ដឹងអំពីបច្ចេកវិទ្យាឌីជីថល ដូចជាការប្រើប្រាស់ស្មាតហ្វូន កុំព្យូទ័រ និងជាពិសេសកម្មវិធីកុំព្យូទ័រដូចជា Excel ។
- អ្នកសារព័ត៌មានដែលផលិតរឿងរ៉ាវជាច្រើន ហើយដែលតម្រូវឱ្យប្រើទិន្នន័យច្រើន។
- អ្នកសារព័ត៌មានដែលប្រាថ្នាចង់រៀនជំនាញថ្មីៗ ដើម្បីបង្កើនគុណភាពនៃការរាយការណ៍របស់ពួកគេ។

## ការរំពឹងទុក

អ្នកចូលរួមនឹងទទួលបានសមត្ថភាពក្នុងការបង្ហាញទិន្នន័យស្មុគស្មាញតាមរយៈទម្រង់រូបភាពគួរឱ្យទាក់ទាញ និងបង្កើនភាពច្បាស់លាស់ ព្រមទាំងជំរុញទំនាក់ទំនងកាន់តែប្រសើរជាមួយអ្នកអាន ឬអ្នកមើលរបស់ពួកគេផងដែរ។

## លក្ខខណ្ឌនៃការជ្រើសរើស

អ្នកចូលរួមត្រូវជា **អ្នកសារព័ត៌មាន**។ អង្គការអូឌីស៊ីលើកទឹកចិត្ត ស្ត្រី ជនជាតិដើមភាគតិច ជនដែលមានពិការភាព និងជនស្រលាញ់ភេទដូចគ្នា ឱ្យចូលរួម។

## តម្រូវការ

អ្នកចូលរួមត្រូវមានកុំព្យូទ័រផ្ទាល់ខ្លួន និងមូលដ្ឋានគ្រឹះនៃជំនាញកុំព្យូទ័រ។

## កាលបរិច្ឆេទសំខាន់ៗ

- បើកឱ្យចុះឈ្មោះចូលរួម៖ ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២៤
- បិទការចុះឈ្មោះចូលរួម៖ ថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៤
- ប្រកាសឈ្មោះអ្នកដែលត្រូវបានជ្រើសរើសចូលរួមវគ្គបណ្តុះបណ្តាល៖ ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៤
- រៀបចំវគ្គបណ្តុះបណ្តាល៖ ថ្ងៃទី២៩-៣០ ខែសីហា ឆ្នាំ២០២៤

សម្រាប់ការចុះឈ្មោះ៖ https://forms.office.com/r/WUNcsk2jkz ឬធ្វើការស្កេន QR កូដខាងក្រោម

## របៀបវារៈ

| ពេលវេលា | មាតិកា | អ្នកសម្របសម្រួល |
|---|---|---|
| | ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៤ | |
| 8:00 – 8:30 | ចុះឈ្មោះ | ក្រុមការងារអូឌីស៊ី |
| 8:30 - 8:35 | មតិស្វាគមន៍ | អ្នកស្រី គឹម ឈួនវួច<br>អ្នកសម្របសម្រួលកម្មវិធីនៃអូឌីស៊ី |
| 8:35 – 8:45 | ការណែនាំខ្លួន | អ្នកចូលរួមទាំងអស់ |
| 8:45 – 8:55 | តេស្តសាកល្បងមុនវគ្គបណ្តុះបណ្តាល | |
| 8:55 – 9:10 | សម្រាកអាហារសម្រន់ | |
| 9:10 – 9:40 | ស្វែងយល់អំពីទិន្នន័យ | លោក បាន ចន្ទផល្លា<br>បណ្ណាធិការ-អ្នកស្រាវជ្រាវនៃអូឌីស៊ី |
| 9:40 – 10:40 | គោលការណ៍ទស្សនីយកម្មទិន្នន័យ | លោក វង្ស ពិសិដ្ឋ<br>អ្នកសម្របសម្រួលផ្នែកកសាងសមត្ថភាពនៃអូឌីស៊ី |
| 10:40 – 11:10 | សេចក្តីណែនាំអំពី Flourish | |
| 11:10 – 12:00 | ការអនុវត្តទស្សនីយកម្មតាមការណែនាំ | |
| 12:00 – 13:30 | សម្រាកអាហារថ្ងៃត្រង់ | អ្នកចូលរួមទាំងអស់ |
| 13:30 – 14:30 | អនុវត្តទស្សនីយកម្មទិន្នន័យជាមួយ Flourish (តាមក្រុម) | |
| 14:30 – 14:50 | ឆ្លុះបញ្ចាំងអំពីទស្សនីយកម្មទិន្នន័យតាមក្រុមនីមួយៗ | |
| 14:50 – 15:05 | សម្រាកអាហារសម្រន់ | |
| 15:05 – 16:05 | អនុវត្តទស្សនីយកម្មទិន្នន័យជាមួយ Flourish (រៀងខ្លួន) | |
| | ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៤ | |
| 8:30 – 9:30 | ដំណើរការនៃការរៀបរាប់រឿងទិន្នន័យ (Data storytelling process) | លោក វង្ស ពិសិដ្ឋ |

| ពេលវេលា | មាតិកា | អ្នកសម្របសម្រួល |
|---|---|---|
| | | អ្នកសម្របសម្រួលផ្នែកកសាងសមត្ថភាពនៃអូឌីស៊ី |
| 9:30 – 9:45 | សម្រាកអាហារសម្រន់ | អ្នកចូលរួមទាំងអស់ |
| 9:45 – 10:25 | សេចក្តីណែនាំអំពីទស្សនីយកម្ម៖ Scattered plot, Treemap, Juxtaposed Images | លោក វង្ស ពិសិដ្ឋ អ្នកសម្របសម្រួលផ្នែកកសាងសមត្ថភាពនៃអូឌីស៊ី |
| 10:25 – 11:25 | ការអនុវត្តទស្សនីយកម្មតាមការណែនាំ | |
| 11:25 – 12:00 | អនុវត្តទស្សនីយកម្មទិន្នន័យជាមួយ Flourish (តាមក្រុម) | អ្នកចូលរួមទាំងអស់ |
| 12:00 – 13:30 | សម្រាកអាហារថ្ងៃត្រង់ | |
| 13:30 – 13:50 | ឆ្លុះបញ្ចាំងអំពីទស្សនីយកម្មទិន្នន័យតាមក្រុមនីមួយៗ | |
| 13:50 – 14:45 | ការអនុវត្តគម្រោងការរៀបរាប់រឿងទិន្នន័យ (រៀងខ្លួន) | |
| 14:45 – 15:00 | សម្រាកអាហារសម្រន់ | |
| 15:00 – 15:50 | បន្តការអនុវត្តគម្រោងការរៀបរាប់រឿងទិន្នន័យ (រៀងខ្លួន) | |
| 15:50 – 16:00 | តេស្តសាកល្បងក្រោយវគ្គបណ្តុះបណ្តាល | |
| 16:00 – 16:05 | ការវាយតម្លៃវគ្គបណ្តុះបណ្តាល | |
| 16:05 – 16:10 | បិទកម្មវិធី | ក្រុមការងារអូឌីស៊ី |

*ចំណាំ៖ របៀបវារៈអាចនឹងមានការផ្លាស់ប្តូរដោយមិនមានការជូនដំណឹង។*

## អំពីអ្នករៀបចំវគ្គបណ្តុះបណ្តាល

អង្គការទិន្នន័យអំពីការអភិវឌ្ឍ ហៅកាត់ថា អូឌីស៊ី បានទទួលការគាំទ្រពី ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) តាមរយៈអង្គការសុខភាពគ្រួសារអន្តរជាតិ (FHI360) ដើម្បីអនុវត្តគម្រោងគាំទ្រអង្គការសង្គមស៊ីវិល៖ ចង្កោមអង្គការសង្គមស៊ីវិល។ វគ្គបណ្តុះបណ្តាលនេះគឺជាផ្នែកមួយនៃការអនុវត្តគម្រោង។